# ការសំភាសន៍របស់ ពល ងែត

កៈ អ្នកដែរសំភាសន៍ ជាង ស៊ីអាវ ខៈ អ្នកដែរអោយគេសំភាសន៍ ពល ងែត

កៈ
បាទចឹងជាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំបានសំភាសន៍ដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ
ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំលើងដោយសាលាមួយដែរនៅសហរដ្ឋអាមេរិចចឹងហាសអ៊ុំ បាទអ៊ុំចឹងដោយសារតែសាលាមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីអោយពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្តាយនឹងចឹងហាសអ៊ុំបាទចឹង
ហើយនៅពេលដែរខ្ញុំសំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍របស់អ៊ុំនឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ
បាទចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ យល់ព្រមតា

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ
ហើយការសំភាសន៍ត្រូវបានធ្វើនៅថ្ងៃទី24 ខែ1 ឆ្នាំ2018អ៊ុំ ហើយបានធ្វើនៅ ភូមិ4
សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញចឹងហាសអ៊ុំ
ចឹងសំរាប់អ៊ុំឈ្មោះពេញរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខៈ ខ្ញុំឈ្មោះពល ងែត

កៈ ឈ្មោះពល ងែត ណាអ៊ុំ ចុះមានឈ្មោះ ហៅក្រៅទេអ៊ុំ?

ខៈ អត់ផងនឹង

កៈ ចុះកាលពីនៅតូចមានធ្លាប់នរណាគេហៅឈ្មោះអីផ្សេងពីនឹងទេអ៊ុំ?

ខៈ អត់មានទេ

កៈ អូបាទចុះអ៊ុំសព្វថ្ងៃអ៊ុំអាយុប៉ុន្មានទៅអ៊ុំ?

ខៈ អើរអាយុ57ឆ្នាំ

កៈ អ៊ុំអាយុ57ឆ្នាំ ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំមានចងចាំទេ?

ខៈ កើតនៅឆ្នាំ1962

កៈ ឆ្នាំ1962 ចុះថ្ងៃខែអ៊ុំមានចងចាំអត់អ៊ុំ ដូចជានៅថ្ងៃណាខែណា អ៊ុំ?

ខៈ ខ្ញុំកើតនៅថ្ងៃពុធ

កៈ ចុះទីប៉ុន្មានអ៊ុំមានចងចាំទេអ៊ុំ?

ខៈ ខែ3

កៈ ខែ3ចុះទីប៉ុន្មានអ៊ុំមានចងចាំអត់អ៊ុំ ដូចជាទី3 ទី4 ទី5អីចឹងហាសអ៊ុំ?

ខៈ អត់ទេ

កៈ អ៊ុំចាំទេណាអ៊ុំ ឆ្នាំច័ន្ទគតិអ៊ុំឆ្នាំអីគេអ៊ុំ ដូចជាឆ្នាំជូត ឆ្លូវ ខាល ថោះអីអ៊ុំឆ្នាំអីគេដែរ?

ខៈ ខ្ញុំឆ្នាំឆ្លូវ

កៈ អ៊ុំឆ្នាំឆ្លូវហោស ទីកន្លែងដែរអ៊ុំកើតអ៊ុំកើតនៅណាដែរអ៊ុំ?

ខៈ នៅឈ្វូក

កៈ នៅឈ្វូក នៅភូមិអី ឃុំអី ស្រុកអី អ៊ុំ?

ខៈ នឹងគេហៅស្រុកឈ្វូកហាស

កៈ ស្រុកឈ្វូក ប៉ុន្តែភូមិអីអ៊ុំ?

ខៈ ភូមិដំណាក់ទ្រព្យ

កៈ ភូមិដំណាក់ទ្រព្យ ចុះឃុំអីគេអ៊ុំ?

ខៈ ឃុំនឹងក៏ឃុំដំណាក់ទ្រព្យដែរ

កៈ ឃុំដំណាក់ទ្រព្យដែរ ស្រុកឈ្វូក ខេត្តកំពត ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ខ្ញុំមានបងប្អូន6នាក់

កៈ មាន6នាក់ចុះមានប្រុសប៉ុន្មាន ហើយស្រីប៉ុន្មាននាក់ទៅអ៊ុំ?

ខ៖ មានប្រុស3នាក់ នឹងស្រី3នាក់

ក៖ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំជាកូនទី3

ក៖ ជាកូនទី3ណាអ៊ុំ
ចុះអ៊ុំអាចប្រាប់ឈ្មោះបងប្អូនរបស់អ៊ុំបានទេអ៊ុំចាំអត់អ៊ុំដូចជាបងធំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ចាំតា

ក៖ គាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឈ្មោះ ពៅ ចាន់នី

ក៖ ចុះបងទី2អ៊ុំ?

ខ៖ បងទី2ឈ្មោះ ភ័ក្រ

ក៖ ចុះទី3អ៊ុំណាអ៊ុំ ចុះទី4វិញ?

ខ៖ ទី4នឹងឈ្មោះ ការ យ៉ន

ក. ទី4ឈ្មោះ ការ យ៉ន ចុះទី5វិញអ៊ុំ?

ខ៖ ទី5ឈ្មោះ អា រុណ

ក៖ ចុះទី6អ៊ុំ ?

ខ៖ ឈ្មោះ អា រិន

ក៖
ចុះអ៊ុំមានចងចាំសាច់រឿងអីកាលដែរអ៊ុំនៅជាមួយបងរឺប្អូនរបស់អ៊ុំកាលពីនៅក្មេងធ្លាប់បានធ្វើអីជាមួយគ្នាទេអ៊ុំ ដូចជាធ្លាប់លេងបិទពួនអីចឹងហាសអ៊ុំ?

ខ៖ អត់ផងម៉ែឪរបស់ខ្ញុំមកនៅជាមួយគ្នាខ្ញុំមកនៅជាមួយគេ

ក៖ អូមកនៅជាមួយគេតាំងពីតូចមកហោសអ៊ុំ?

ខ៖ ចានឹងហើយ

ក៖ ចឹងអ៊ុំអត់ដែរបានទៅស្រែអីជាមួយបងប្អូនរបស់អ៊ុំទេណាអ៊ុំ?

ខ៖ បើនិយាយរួមទៅមិនដែរបានរួមរស់ជាមួយបងប្អូនផងសំរាប់ខ្ញុំ

ក៖ ប៉ុន្តែអ៊ុំបានបែកគ្នាជាមួយបងប្អូនរបស់អ៊ុំនឹងនៅអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ នៅអាយុ6ឆ្នាំ

ក៖ នៅអាយុ6ឆ្នាំចឹងនៅក្មេងៗទេណាអ៊ុំ?

ខ៖ នៅតូចៗនឹង

ក៖ អូចឹងអ៊ុំមានដឹងថាអ៊ុំចូលចិត្តលេងអីជាមួយពួកគាត់អត់អ៊ុំ?

ខ៖ អត់ដែរបានលេងអីជាមួយគ្នាផងនឹង
ដូចថាសព្វថ្ងៃចឹងទៅដឹងថាទីលំនៅយើងនៅនឹងចឹងទៅយើងទៅលេងបងប្អូនធម្មតាចឹង

ក៖ អូចឹងហោស ចុះបងធំរបស់អ៊ុំសព្វថ្ងៃនឹងគាត់រស់នៅណាដែរទៅអ៊ុំ?

ខ៖ រស់នៅស្រុកឈូកនឹង

ក៖ រស់នៅស្រុកឈូកនឹង ប៉ុន្តែគាត់ធ្វើអីគេដែរអ៊ុំ?

ខ៖ គាត់ធ្វើស្រែពួកនឹង

ក៖ គាត់ធ្វើស្រែណាអ៊ុំ ចុះបងទី2គាត់ធ្វើអីគេដែរអ៊ុំ?

ខ៖ បងទី2គាត់ធ្វើទាហ៊ានពីដើម

ក៖ ប៉ុន្តែគាត់នៅណាវិញអ៊ុំ?

ខ៖ នៅស្រុកឈូកនឹងដែរនឹង

ក៖ នៅស្រុកឈូកនឹងដែរហោសអ៊ុំ ចុះប្អូនទី4គាត់ធ្វើអីគេដែរអ៊ុំ?

ខ៖ ពួកនឹងសុទ្ធតែធ្វើស្រែនឹង

ក៖ គាត់នៅស្រុកឈូកនឹងដែរ?

ខ៖ ចានៅណុង

ក៖ ចុះទី5នឹងទី6គាត់នៅស្រុកឈូកណុងដែរ?

ខ៖ នៅជុំគ្នានឹង

ក៖ អូខុសតែអ៊ុំអ៊ុំមកនៅភ្នំពេញតែម្នាក់អែងណាអ៊ុំ?

ខ៖ ខ្ញុំនៅបើនិយាយរួមទៅខ្ញុំនៅជាមួយគេនៅកោះធំណោះទេ
ប៉ុន្តែពេលដែរខ្ញុំដឹងក្តីទៅខ្ញុំបានមកភ្នំពេញតែខ្ញុំទេណា

ក៖ អូបាទអ៊ុំប៉ុន្តែអ៊ុំមកយកគ្រួសារនៅភ្នំពេញនឹង?

ខ៖ ចាមកយកនៅភ្នំពេញ

ក៖ បាទចុះឪពុករបស់អ៊ុំគាត់ឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឪពុករបស់ខ្ញុំគាត់មានឈ្មោះ ពល ម៉ាច

ក៖ ចុះគាត់អាយុប៉ុន្មានអ៊ុំមានចងចាំទេ?

ខ៖ គាត់ស្លាប់ហើយគាត់ស្លាប់ចិតជាងគាត់ស្លាប់នឹងអាយុ75ឆ្នាំ

ក៖ គាត់ស្លាប់នៅអាយុ75ឆ្នាំណាអ៊ុំ?

ខ៖ គាត់ស្លាប់នឹងបើអាយុគាត់ប្រហែលជាអាយុ75ឆ្នាំអ៊ុំទេណ

ក៖ អូគាត់អាយុ75ឥឡូវហោស ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាអ៊ុំមានចងចាំទេអ៊ុំ?

ខ៖ អត់ទេអត់ចាំទេ មិនដែរសួរមិនដែរអីទេ

ក៖ បាទចឹងសំរាប់ឪពុករបស់អ៊ុំគាត់កើតនៅឆ្នាំ1943អ៊ុំ ចុះគាត់កើតនៅណាអ៊ុំដឹងទេ?

ខ៖ អត់អត់ដែរសួរពីព្រោះអីគាត់អត់មានការគ្រប់គ្រងអីជាមួយយើង
ហើយអត់មានពិភាក្សាអីជាមួយយើងផងនឹង

ក៖ បាទអ៊ុំចុះម្តាយរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់មានឈ្មោះយាយ អ៊ុច ប៉ុន្តែស្លាប់បាត់អស់ហើយនឹង

កៈ ប៉ុន្តែគាត់អាយុប៉ុន្មានអ៊ុំមានចងចាំទេ?

ខៈ គាត់អាយុស្ពុរៗៗគ្នានឹង

កៈ គាត់អាយុ74-75ឆ្នាំដូចគ្នាណាអ៊ុំចឹងគាត់កើតនៅឆ្នាំ1943ដូចគ្នាណាអ៊ុំ?

ខៈ ចាដូចតែគ្នានឹង

កៈ ចុះឪពុករបស់អ៊ុំគាត់ធ្វើអីសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ ខ្ញុំមិនសូវដឹងថាគាត់ធ្វើអី ប្រវត្តិគាត់ធ្វើអីខ្ញុំមិនសូវដឹងផងនឹង ពីព្រោះអីកាលពីឆ្នាំ1985-1986នឹងគាត់ស្លាប់អស់ ដល់ពេលចឹងទៅយើងអត់សួរប្រវត្តិគាត់រកស៊ុអី លឺថាប្រវត្តិរបស់គាត់ធាក់ស៊ីខ្លូ ធាក់អីចឹងហាស

កៈ អូធាក់ស៊ីខ្លូណាអ៊ុំ ចុះឪពុករបស់អ៊ុំគាត់ជាមនុស្សកាច រឺមួយក៏ស្លូតអ៊ុំមានដឹងទេកាលពីជំនាន់ណុងហាស?

ខៈ គាត់ដូចជាអត់កាចផងឪរបស់ខ្ញុំ

កៈ គាត់ស្លូតទេណាអ៊ុំ ចុះម្តាយរបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ មានចងចាំទេ?

ខៈ គាត់ធ្វើស្រែនឹង

កៈ គាត់ធ្វើស្រែណាអ៊ុំ?

ខៈ នៅស្រុករបស់ខ្ញុំធ្វើតែស្រែទេ

កៈ ចុះគាត់ជាមនុស្សបែបណាដែរអ៊ុំស្លូត រឺមួយក៏កាចដែរអ៊ុំ?

ខៈ គាត់នៅក្នុងភូមិណុងគេគោរពគាត់ ព្រោះធ្វើឆ្មប់នោះ

កៈ ម្តាយរបស់អ៊ុំណា ប៉ុន្តែគាត់កាចជាមួយកូនចៅទេអ៊ុំ?

ខៈ អត់ទេ

កៈ គាត់ស្លូតដែរណាអ៊ុំ ចុះអ៊ុំមានចងចាំសាច់រឿងអីកាលដែរអ៊ុំនៅជាមួយពួកគាត់ទេ?

ខៈ អត់ពីព្រោះអីយើងនៅតូចកាលណុង ខ្ញុំអាយុ6ឆ្នាំ

កៈ អ៊ុំមិនសូវដឹងអីទេណា អ៊ុំនៅដើរលេងគិតលេងជាមួយមិត្តភក្តិណាអ៊ុំ?

ខ៖ ចាខ្ញុំមិនសូវដឹងទេ ហើយដល់ពេលហើយចូលអាពលពតដែរម្តងនឹង

ក៖ អូចឹងចូលអាពតតែម្តងទៅ
ចុះសូម្បីតែម្តាយឪពុករបស់អ៊ុំក៏គាត់មិនដែរប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងដែរណាអ៊ុំ?

ខ៖ អត់ទេ

ក៖ ចុះម្តាយរបស់អ៊ុំគាត់មានធ្លាប់ប្រាប់ឈ្មោះយាយតាខាងម្តាយទៅប្រាប់អ៊ុំអត់អ៊ុំ?

ខ៖ អត់ស្គាល់ទេ

ក៖ អត់ស្គាល់ ចុះខាងឪពុកក៏អត់ស្គាល់ដែរហោសអ៊ុំ?

ខ៖ អត់ពីព្រោះអីនឹង

ក៖ អ៊ុំនៅតូចៗដែរណា?

ខ៖ គាត់បានអោយខ្ញុំទៅគេហោស ដូចថាទៅរស់នៅជាមួយគេទៅយាយតាអី
យើងអត់ស្គាល់

ក៖ អូបាទអ៊ុំ ចុះអ៊ុំមកនៅទីក្រុងភ្នំពេញនឹងយូរនៅអ៊ុំ?

ខ៖ ខ្ញុំមកនៅតាំងពៅដាច់អាពតហោស

ក៖ អូតាំថពីបែកអាពតចឹងប្រម៉ានប្រហែលជា30-40ឆ្នាំហើយមែនទេអ៊ុំ?

ខ៖ ចានឹងហើយខ្ញុំមកដល់ពេលដែរខ្ញុំដឹងក្តីមកខ្ញុំរត់ទៅរកឪហោស
ឪបង្កើតនឹងមកនៅទួលទំពុងនឹងហើយគាត់អោយទៅក5ហើយគាត់លក់ផ្ទះលក់អីអស់ទៅ
ហើយខ្ញុំមកនៅក5នឹងទៅ

ក៖ ចឹងមានន័យថាអ៊ុំមកនៅភ្នំពេញនឹងប្រហែល39ឆ្នាំអ៊ុំ?

ខ៖ នឹងហើយមករស់នៅយូរហើយ

ក៖ ចុះអ៊ុំមានកូនចៅណា រឺក៏សាច់ញ្ញាតិណាដែររស់នៅក្រៅពីស្រុកខ្មែរទេអ៊ុំ?

ខ៖ អត់មានផងនឹង

ក៖ ចឹងកូនចៅរបស់អ៊ុំសុទ្ធតែនៅស្រុកខ្មែរទាំងអស់ទេណាអ៊ុំ?

ខ៖ ខ្ញុំមានកូនតែមួយនឹង

ក៖ អូបាទអ៊ុំមីងមិញនឹងហោសអ៊ុំ?

ខ៖ អត់ទេ កូនរបស់ខ្ញុំកូនប្រុស

ក៖ អូបាទអ៊ុំប្តីរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ប្តីរបស់ខ្ញុំលែងគ្នាយូរហើយនឹង

ក៖ ចុះអ៊ុំមានចងចាំថាគាត់មានឈ្មោះអ៊ុំទេអ៊ុំ?

ខ៖ ឈ្មោះ ឆាង

ក៖ ឈ្មោះឆាង ណាអ៊ុំ ចុះអ៊ុំមានចងចាំថាអ៊ុំបានរៀបអាពាហ៍ពិពាហ៍នៅពេលណាដែរទៅអ៊ុំ?

ខ៖ កាលពីជំនាន់ណុងពេលដែរបែកអាពតទៅ ចាស់ជាអ្នកផ្សំផ្គុំតា

ក៖ ចុះឆ្នាំណាអ៊ុំមានចងចាំទេ ដូចជាឆ្នាំ1970ប៉ុន្មានរឺក៏80ប៉ុន្មានចឹងហាសអ៊ុំមានចងចាំទេ?

ខ៖ ឆ្នាំ1979

ក៖ ដាច់អាពតភ្លាម ឆ្នាំ1979តែម្តងហោសអ៊ុំ?

ខ៖ នឹងហើយ

ក៖ ចឹងមានន័យថានៅឆ្នាំ1979ភ្លាមដាច់អាពតភ្លាមអ៊ុំការតែម្តងហោសអ៊ុំ?

ខ៖ មិនទាន់បែកទេពីព្រោះអីកាលណុងពេលដែរកំពុងតែវៃគ្នាហាសគេរត់ទៅកើតនោះ ហើយជីដូនមួយគេអោយសែនអោយអីយាយតាអីនឹង

ក៖ ចឹងមានន័យថាអ៊ុំការនឹងអស់រយះពេលអស់39ឆ្នាំអ៊ុំ?

ខ៖ ចានឹងហើយ

ក៖ ចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងដូចជាម្តាយឪពុករបស់ងុំជាអ្នកផ្សំផ្គុំអោយរឺក៏អ៊ុំជាអ្នករៀបចំដោយខ្លួនអែងដែរអ៊ុំ?

ខ៖ មីង

កៈ មីងណាអ៊ុំ អូពេលណុងអ៊ុំនៅជាមួយមីងហើយណាអ៊ុំ ?

ខៈ ចេះតែរត់សោត់ទៅ

កៈ ចុះពេលដែរប្តីរបស់អ៊ុំចូលស្តីដណ្តឹងអ៊ុំនឹងដូចជាមានជាជំនូនអត់អ៊ុំ?

ខៈ មានជាជំនូនអីបើនៅជំនាន់ណុងរកតែអង្ករស៊ីគ្មានផងនឹង

កៈ អូចឹងពេលដែរយើងការយើងចែកគ្នាចេញទៅណាអ៊ុំ?

ខៈ អត់ទេ ដូចថានេះគ្រាន់ជាងអាពតបន្តិច ពេលអាពតដូចថាគេយកទៅ10នាក់ចឹងទៅគេអោយចាប់ដៃគ្នាទៅ

កៈ អូលក្ខណះគេយកទៅចាប់ដៃគ្នាទៅហើយការទៅ តាមអាពតណាអ៊ុំ?

ខៈ នឹងហើយធ្វើចឹង ហើយយើងសច្ចារៀងៗខ្លួនទៅ

កៈ ចុះចឹងអ៊ុំអាចប្រាប់ខ្ញុំបានទេថាអ៊ុំបានជួបប្តីរបស់អ៊ុំពេលណាអីទេអ៊ុំ?

ខៈ ពេលដែរជួបនឹងគឺជួបនៅបាត់ដំបងនឹង

កៈ ជួបនៅបាត់ដំបងណាអ៊ុំ ប៉ុន្តែអាពតគេបង្ខំអោយយើងចាប់គូរតែម្តងរឺមួយក៏យើងឃើញគ្នាអ៊ុំ?

ខៈ អត់ទេយើងរត់ហោស
មិនពេលដែរបែកពីអាពតមិនយើងចេះតែរត់ទៅៗពេលខ្មែរក្រហមឃ្លូនដេញបាញ់គ្នាហោស

កៈ បាទអ៊ុំ ប៉ុន្តែយើងជួបគ្នាចៃដន្យតាហីអ៊ុំ?

ខៈ ជួបគ្នាចៃដន្យនឹង

កៈ ប៉ុន្តែអ៊ុំជួបគ្នារយះពេលប៉ុន្មានដែរបានអ៊ុំបានរៀបអាពាហ៍ពិពាហ៍ដែរអ៊ុំ?

ខៈ បើនិយាយរួមនឹងវាមិនបានរៀបហាស

កៈ អូអត់បានរៀបផងហោសអ៊ុំ ប៉ុន្តែយើងបានសែនអីត្រឹមត្រូវដែរតាហីអ៊ុំ?

ខៈ ចាបាន

កៈ ចុះអ៊ុំចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុន្មានដែរអ៊ុំ?

ខៈ អត់ចេះកាលពីអាពតគ្មានចេះអីទេ

កៈ អូប៉ុន្តែអ៊ុំធ្លាប់បានចូលរៀនអត់អ៊ុំ?

ខៈ អត់

កៈ អត់ទេណអ៊ុំ?

ខៈ អត់សោះតែម្តងនឹង

កៈ បាទអ៊ុំ ចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរទេអ៊ុំ?

ខៈ អត់ចេះទេ

កៈ ចុះភាសាអង់គ្លេស ថៃអី?

ខៈ អត់ចេះទេ

កៈ អត់ចេះទេណអ៊ុំ វៀតណាមអ៊ុំចេះដែរ

ខៈ អត់ចេះ

កៈ ចុះអ៊ុំធ្លាប់មានមិត្តភក្តិណាដែរស្និទ្ធស្នាលដែរធំធាត់មកជាមួយគ្នាអត់អ៊ុំ ដូចជាកាលនៅក្មេងៗមុនអាពតអីអ៊ុំមានមិត្តភក្តិស្គាល់គ្នា ហើយជិតស្និទ្ធអត់អ៊ុំ?

ខៈ មានប៉ុន្តែភ្លេចគ្នាអស់ហើយនឹង

កៈ ប៉ុន្តែអ៊ុំមានចងចាំឈ្មោះពួកគាត់អត់អ៊ុំ?

ខៈ ភ្លេចឈ្មោះគ្នាអស់ហើយនឹង

កៈ
អូបាទប៉ុន្តែអ៊ុំមានចងចាំថាកាលពេលដែរនៅក្មេងៗអ៊ុំមានធ្លាប់ធ្វើអីជាគ្នាអត់អ៊ុំដូចជាទៅស្រែ រឺទៅធ្វើការអីជាមួយគ្នាចឹងហាស?

ខៈ កាលណុងខ្ញុំនៅជាមួយគេនឹងគេអោយឃ្វាលតែគោ

កៈ អូឃ្វាលគោណអ៊ុំ?

ខ៖ ឃ្វាលគោកាលពីនៅជាមួយគេនឹងហាស

ក៖ បាទអ៊ុំប៉ុន្តែមានអោយដកស្ទូងដែរតាហីអ៊ុំ?

ខ៖ នៅស្រុកកោះធំអត់មានដកស្ទូងអីទេមានតែពោតអីទេ
ខ្ញុំគេអោយមើលតែគោអាគោធំហោស

ក៖ បាទអ៊ុំបាទ ចុះអ៊ុំមានធ្លាប់ទៅធ្វើការនៅវាលស្រែអត់អ៊ុំ នៅស្រែចំការហោស?

ខ៖ ធ្វើតា

ក៖ អូធ្វើហោសអ៊ុំ ប៉ុន្តែលក្ខណះមើលគោ ដកស្ទូងអីនឹងហោសអ៊ុំ?

ខ៖ មើលគោធ្វើស្មៅស្រូវ ធ្វើស្មៅគោអីនឹងហាស

ក៖ អូបាទអ៊ុំចុះអ៊ុំមានធ្លាប់ចិញ្ចឹមសព្វដូចជា មាន់ ទា គោអីអត់អ៊ុំ?

ខ៖ អត់ទេ

ក៖ អត់ទេណអ៊ុំ ប៉ុន្តែអ៊ុំមានធ្លាប់លក់ដូរអត់អ៊ុំ?

ខ៖ អត់ទេ

ក៖ អត់ដែរណអ៊ុំ ចុះអ៊ុំមានធ្លាប់ធ្វើការអីគេនៅក្នុងជីវិតដែរអ៊ុំ
ធ្លាប់ធ្វើការអីគេខ្លះទៅនៅក្នុងជីវិតរបស់អ៊ុំហាសអ៊ុំ?

ខ៖ អត់ដែរធ្វើអីផងនឹង បើអត់ចេះអក្សរផងនឹង

ក៖ ប៉ុន្តែអ៊ុំធ្លាប់លក់អីសំរាប់ចិញ្ចឹមជីវិតដែរចឹងហាសអ៊ុំ កាលអ៊ុំនៅជាមួយប្តីរបស់អ៊ុំ
រឺមួយក៏ពេលមុននៅជាមួយប្តីរបស់អ៊ុំចឹងហាសអ៊ុំ?

ខ៖ ខ្ញុំពីមុនខ្ញុំលក់ត្រកួន លក់អីនឹង លក់ត្រកួន លក់ប្រលឹតអីនឹង

ក៖
អូបាទចឹងសំរាប់តាំងពីក្មេងរហូតមកដល់ពេលនេះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអី
គេខ្លះដែរអ៊ុំ?

ខ៖ អត់ផង

កៈ អត់មានការផ្លាស់ប្តូរអីទេណអ៊ុំ ចុះអ៊ុំគិតថាកាលពីនៅក្មេងយ៉ាងម៉េចដែរ ហើយឥឡូវនឹងយ៉ាងម៉េចដែរចឹងហាសអ៊ុំ?

ខៈ នៅក្មេងយើងចេះតែស៊ីឈ្នួលលាងចានអីអោយគេដែរចឹងទៅ

កៈ អូបាទដល់ពេលឥឡូវនឹងអ៊ុំ?

ខៈ ឥឡូវឈឺ

កៈ ឥឡូវឈឺណអ៊ុំ ចុះដល់ពេលដែរអ៊ុំមានប្តីអ៊ុំបានធ្វើអីគេទៅអ៊ុំ?

ខៈ ខ្ញុំបានលែងគ្នាយូរហើយនឹង

កៈ ប៉ុន្តែនៅពេលដែរអ៊ុំការហើយភ្លាមៗអ៊ុំធ្វើអីគេទៅ?

ខៈ កាលណុងពេលដែរបែកមកភ្លាមៗនឹងខ្ញុំលាងចានអោយគេ ស៊ីឈ្នួលលាងអោយគេ

កៈ អូចឹងអ៊ុំលាងចានណអ៊ុំ ?

ខៈ លាងចានគុយទាវ លាងចានអីចឹងហាស

កៈ អស់រយះពេលប៉ុន្មានឆ្នាំទៅអ៊ុំ?

ខៈ ប្រហែលជា3-4ឆ្នាំអីដែរនឹង

កៈ ប៉ុន្តែគេ.......

ខៈ ពីព្រោះស៊ីឆ្អែតនៅនឹងអីនឹង

កៈ អូបាទអ៊ុំចឹងហោសអ៊ុំ?

ខៈ ចេះតែនៅទៅនឹង

កៈ ប៉ុន្តែគេគិតប្រាក់ខែអោយយើងប៉ុន្មានដែរទៅអ៊ុំ?

ខៈ កាលពីជំនាន់ណុងបើគិតជាលុយខ្មែរវិញវាបាន10$លុយធំដែរនឹង

កៈ បាន10$ប៉ុន្តែកាលពីជំនាន់ណុងលុយថ្លៃហាសណាអ៊ុំ?

ខៈ លុយថ្លៃ

កៈ កាលជំនាន់ណុងលុយថ្លៃហាសណាអ៊ុំបាន10$ចាយបានមួយខែទៅពីរខែហោស?

ខៈ អត់ទេកាលណុងមាសមួយជី2000-3000នឹង

កៈ មាសមួយជី3000ណាអ៊ុំ
ចុះតាំងពីក្មេងរហូតមកដល់ពេលនេះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខៈ ខ្ញុំគ្មានទៀងទេ

កៈ ប៉ុន្តែអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខៈ ខ្ញុំចូលចិត្តស្លម្ជូ ចៀន

កៈ ចុះឆា ស្ងោ កកូរ ការីអីអ៊ុំមានចូលចិត្តទេ?

ខៈ អត់សូវទេ

កៈ ចឹងអ៊ុំចូលចិត្តតែម្ជូរហើយនឹងចៀន ?

ខៈ ចាចូលចិត្ត

កៈ ចុះល្បែងប្រជាប្រិយ៍ដែរអ៊ុំចូលចិត្តលេងតាំងពីក្មេងរហូតមកដល់ពេលនេះហាស
ដូចជាល្បែង ចោលឈូង បោះអង្គុញ ទាញព្រាត លាក់កន្សែង អីចឹងហាស?

ខៈ ខ្ញុំអត់ដែរបានលេងផងនេះតាំងពីតូចមកនឹង ដល់អាយុប៉ុណ្ណឹងហាស

កៈ ប៉ុន្តែអ៊ុំមានធ្លាប់លេងល្បែងអីគេខ្លះដែរ លេងខ្វង លេងផ្ទាត់កៅស៊ូ
លេងបាញ់កូនឃ្លីអីចឹងហាស?

ខៈ អត់ទេ

កៈ លេងលោតអន្ទាក់អីអ៊ុំអត់ដែរទេណាអ៊ុំ?

ខៈ អត់ទេពីព្រោះអីកាលណុងពេលដែរដឹងក្តីនឹងនៅជាមួយគេ
យើងមិនអាចទៅលេងអីផ្តេសផ្តាសបានផងនឹង

កៈ អូបាទអ៊ុំចឹងហោសអ៊ុំ?

ខៈ យើងនៅក្នុងការគ្រប់គ្រងរបស់គេហាស

កៈ ប៉ុន្តែយើងទៅវត្តអីគេអត់អោយយើងទៅដែរ ឧទាហរណ៍ថាយើងចង់ទៅវត្តលេងអីចឹងហាស?

ខៈ ទៅៗៗគេមានឃាត់អីរឿងទៅវត្តនឹង

កៈ ប៉ុន្តែពេលដែរយើងទៅវត្តទៅអីចឹងទៅពេលយប់យើងតែងតែលេងល្បែងប្រជាប្រិយ៍អីចឹងហាសអ៊ុំ?

ខៈ ខ្ញុំអត់លេងទេខ្ញុំមិនរវីរវល់ទេ

កៈ អូបាទអ៊ុំៗ ចុះអ៊ុំគិតថាអ៊ុំមានចងចាំបទចំរៀងណាដែរអ៊ុំគិតថាអ៊ុំចេះរៀង ហើយរៀនច្រៀងតាំងពីក្មេងមករហូតដល់ពេលនេះហើយអ៊ុំនៅតែចេះច្រៀងទៀតហាសអ៊ុំ?

ខៈ អត់ទេ

កៈ អ៊ុំអត់ចេះច្រៀងទេណាអ៊ុំ?

ខៈ ចាអត់

កៈ ចុះអ៊ុំចូលចិត្តស្តាប់បទចំរៀងអត់អ៊ុំ?

ខៈ មើលតែទូរទស្សន៍អីនឹង

កៈ ចុះបទសម័យរឺមួយក៏បទបុរាណដែរអ៊ុំចូលចិត្តស្តាប់ដែរអ៊ុំ?

ខៈ បើនិយាយរួមទៅចូលចិត្តតែបទបុរាណ បទសម័យមិនចេះស្តាប់ទេ

កៈ អូបាទអ៊ុំប៉ុន្តែអ៊ុំមានចងចាំចំណាងជើងអត់អ៊ុំ?

ខៈ មិនដឹងអីទៅស្អីទេ បើមិនចេះអក្សរផង

កៈ បាទអ៊ុំ ចុះអ៊ុំនៅក្នុងក្រុមគ្រួសាររបស់អ៊ុំនរណាម្នាក់ចេះលេងឧបករណ៍ភ្លេងខ្មែរទេអ៊ុំ?

ខៈ អត់មានទេ

កៈ អត់មានទេណាអ៊ុំ ចុះកូនក្មួយអីក៏អត់ចេះដែរ?

ខ៖ អត់ទេ

ក៖
ចុះតាំងពីក្មេងរហូតមកដល់ពេលនេះផ្ទះរបស់អ៊ុំមានលក្ខណៈយ៉ាងម៉េចដែរអ៊ុំតាំងពីក្មេង
ពេលដែរអ៊ុំនៅជាមួយមីងរបស់អ៊ុំហាសយ៉ាងម៉េចដែរអ៊ុំ?

ខ៖ ផ្ទះធម្មតានៅស្រុកនឹង

ក៖ នៅស្រុកផ្ទះឈើតាហីអ៊ុំ?

ខ៖ ផ្ទះឈើនឹង

ក៖ ប៉ុន្តែឥឡូវនឹងអ៊ុំជួលគេ?

ខ៖ ខ្ញុំជួលគេ

ក៖ ប៉ុន្តែសំរាប់ជួលនឹងតើជួលនៅជាមួយនរណាគេដែរអ៊ុំ?

ខ៖ ចួលនៅ2នាក់

ក៖ ជួលនៅ2នាក់មីងហោសអ៊ុំ?

ខ៖ ចានៅ2នាក់

ក៖ អូបាទអ៊ុំ ចុះកាលនៅផ្ទះអ៊ុំនៅស្រុកនឹងនរណាគេជាអ្នកសាងសងផ្ទះនឹងអ៊ុំ?

ខ៖ កាលដែរបែកពីអាពតមកចេះតែលីឈើលីអីទៅ

ក៖ ចឹងហោសអ៊ុំ
ប៉ុន្តែអ៊ុំមានដឹងថាសាងសងផ្ទះគេប្រើឧបករណ៍អីគេខ្លះសំរាប់សាងសងផ្ទះដែរទេអ៊ុំ?

ខ៖ ស្រុកខ្ញុំមានតែឈើ នឹងឬស្សី

ក៖ ប៉ុន្តែដូចជាឧបករណ៍ដូចជា ដែកគោល
រណាអីចឹងហាសអ៊ុំមានដឹងថាមានអីខ្លះទៀតអត់អ៊ុំ?

ខ៖ វាមិនសូវដឹងដែរពីព្រោះអាការងារនឹងខ្ញុំវាមិនដែរដែលនឹង

កៈ អ៊ុំអត់សួរដឹងទេណាអ៊ុំ ចុះអ៊ុំគិតថាអ៊ុំមានជំនាន់អីដែរអ៊ុំគិតថាអ៊ុំចេះធ្វើខ្លួនអែងតែម្ដង រឺក៏ចេះពីឪពុកម្ដាយរបស់អ៊ុំ ដូចជាវេញវល្លិ៍ កូរស្ករ ធ្វើផ្ដៅ ធ្វើកន្ទេលធ្វើអីចឹងហាសអ៊ុំ ដូចជាល្អីចឹងហាស?

ខៈ អត់ចេះ

កៈ ប៉ុន្តែអ៊ុំរាល់ថ្ងៃនឹងអ៊ុំចេះធ្វើអីគេដែរស្ទាត់តែម្ដងហោសអ៊ុំ?

ខៈ អត់មានធ្វើអីផងនឹង

កៈ ដូចថាអ៊ុំចេះលក់ដូរកាលពីអ៊ុំនៅក្រមុំអីចឹងហាសអ៊ុំ?

ខៈ អត់ទេ

កៈ រឺអ៊ុំមានប្ដីភ្លាមៗចឹងហាស?

ខៈ ខ្ញុំលក់តែត្រកួននឹង

កៈ អូចឹងជំនាន់អ៊ុំលក់ត្រកួនណាអ៊ុំ?

ខៈ លក់ត្រកួន លក់ប្រលឹត

កៈ អូបាទអ៊ុំ ចុះអ៊ុំអាចប្រាប់ពីពេលដែរលំបាកបានទេថា ពេលណាដែរអ៊ុំលំបាកជាងគេនៅក្នុងជីវិតរបស់អ៊ុំបានទេអ៊ុំ?

ខៈ បើនិយាយរួមពិបាកជាងគេគេថាបាន10ហូប10 បាន20ហូប20ពិបាកជាងគេនឹងគឺកូនជក់ថ្នាំញៀននឹង

កៈ អូចឹងហោសអ៊ុំ ប៉ុន្តែឥឡូវនឹងកូនរបស់អ៊ុំនៅតែ........?

ខៈ ជក់ចឹងយកទៅដាក់កន្លែងកែប្រែ2-3ដងហើយនឹង

កៈ ប៉ុន្តែឥឡូវគាត់នៅណាដែរទៅអ៊ុំ?

ខៈ ទៅលក់លាសហើយ

កៈ ទៅលក់លាសបាតហើយណាអ៊ុំ អូប៉ុន្តែកាលពីពលពតអីអ៊ុំដូចជាអត់អីទេណាអ៊ុំ?

ខៈ ពលពតរែកដី លើកត្រណុបនឹងគេ

កៈ អូប៉ុន្តែយ៉ាប់មែនទេអ៊ុំ?

ខៈ គេដាក់មួយកន្លែងចឹងទៅអោយធ្វើមួយថ្ងៃចឹងទៅ មានជំរៅមួយម៉ែត្រ ទទឹងមួយម៉ែត្រ4ជ្រុងនឹងធ្វើចឹងអែង

កៈ ចុះអ៊ុំអាចប្រាប់ថាពេលដែរពលពតគេអោយធ្វើអីគេខ្លះតិចបានទេអ៊ុំ?

ខៈ កាលពីជំនាន់អាពតរែកតែដីនឹងពីព្រោះអីលើកត្រណុបហោស

កៈ បាទអ៊ុំ ចុះគេអោយទៅណាដែរអ៊ុំ?

ខៈ ខ្ញុំគេអោយនៅម្តុំអ្នកលឿងយើងនេះនឹង

កៈ ប៉ុន្តែអ៊ុំអត់មាននៅជាមួយគ្រួសារទៀតទេណាអ៊ុំ?

ខៈ ពេលណុងមិនទាន់មានណា

កៈ ប៉ុន្តែពេលណុងអ៊ុំគេអោយនៅជាមួយមីងទៀតរឺក៏គេអោយទៅនៅជាមួយមិត្តភក្តិដែរអ៊ុំ?

ខៈ អត់ទេគេអោយទៅធ្វើកងចល័តម៉ង

កៈ អូគេអោយធ្វើកងចល័តតែម្តងហោសអ៊ុំ?

ខៈ អោយធ្វើកងចល័តនារីតែម្តងនឹង

កៈ ចឹងចុះអ្នកកងចល័យគេអោយធ្វើអ្នករែកដី រែកអីជាមួយអ៊ុំ?

ខៈ ចាអ្នកកងចល័តគេអោយធ្វើ បើតូចៗបានគេអោយស្ទូងស្រូវ បើអ្នកធំៗគេអោយរែកដីលើកត្រណុបចឹងហាស

កៈ បាទអ៊ុំប៉ុន្មានឆ្នាំបានគេអោយយើងមកនេះវិញទៅអ៊ុំ គេអោយយើងធ្វើប៉ុន្មានខែប៉ុន្មានឆ្នាំដែរទៅអ៊ុំ?

ខៈ បើនិយាយរួមទៅ ខែអោយទឹកចឹងគេអោយសំរាក់ឡើងទៅលើយើងដូចថាយើងធ្វើអីផ្សេងៗទៀតទៅ ដល់ពេលដែរខែទឹកស្រក

កៈ យើងទៅរែកដីទៅ?

ខ៖ គេរអោយទៅរែក
ដូចថាទំណុបគេនៅត្រង់ណាគេត្រូវធ្វើផ្លូវនឹងត្រង់ណាចឹងគេហៅកងចល័តធំៗទៅចឹងហាស

ក៖ អូលក្ខណះទៅឃាំងទឹកឃាំងអីនឹងហោសអ៊ុំ?

ខ៖ នឹងហើយគេធ្វើចឹង

ក៖ ប៉ុន្តែដូចជាពេលណុងដូចជាអ៊ុំនៅអាយុប៉ុន្មានដែរអ៊ុំ អ៊ុំមានចងចាំទេ?

ខ៖ កាលណុងអាយុប្រហែលជាចូល18ឆ្នាំ

ក៖
ចុះនៅអាយុប៉ុន្មានបានគេអោយអ៊ុំមកផ្ទះរបស់មីងអ៊ុំវិញទាល់តែដាច់ពលពតតែម្តងរឺមួយក៏យ៉ាងម៉េចដែរអ៊ុំ?

ខ៖ អត់បានមកផ្ទះផងនឹង បើនរណាគេមកផ្ទះគេយកទៅវៃចោលហើយ

ក៖ ប៉ុន្តែអ៊ុំទាល់តែដាច់ពលពតបានគេអោយអ៊ុំមកផ្ទះមែនទេអ៊ុំ?

ខ៖ ដាច់ពលពតនឹងចេះតែរត់ទៅណា យើងអត់បានមកផ្ទះទេ
យើងចេះតែរត់តាមកងគេទៅណា រត់តាមគេទៅយើងអត់មានទៅផ្ទះរួចទេ

ក៖ អូរហ្វេតមកដល់ខ្មែរក្រហមមែនទេអ៊ុំ?

ខ៖ បើនិយាយនឹងខ្មែរក្រហមនឹងគេនៅពីក្រោយ ហើយពួកអង្គភាពនឹងគេនៅពីមុខ
ហើយបើនរណាគេវិលមកក្រោយទៅរកម៉ែឪវិញគឺស្លាប់ហាស គេយកទៅបាញ់ចោល

ក៖ បាទអ៊ុំ ប៉ុន្តែដូចជាពលពតហើយបានខ្មែរក្រហមមែនទេអ៊ុំ?

ខ៖ អត់ទេខ្មែរក្រហមនឹង ពលពតនឹងខ្មែរក្រហមនឹងជាមួយគ្នា

ក៖ អូជាមួយគ្នានឹងតែម្តងហោសអ៊ុំ?

ខ៖ ចាជាមួយគ្នានឹង

ក៖ ចុះឆ្នាំប៉ែតជាងនឹងគេបានរំដោះនឹងអ៊ុំទៅណាទៅអ៊ុំ?

ខ៖ ចេះតែរត់ៗៗទៅរត់រហូតដល់បាត់ដំបងហោស

ក៖ រត់ដល់បាត់ដំបង អូរត់តែម្តងហោសអ៊ុំ?

ខ៖ ចេះតែទៅទៅណា ហើយបើយើងវិលមកក្រោយវិញម៉េចបានទៅ

ក៖ ប៉ុន្តែយើងជិះអីទៅ រឺមួយក៏យើងដើរទៅអ៊ុំ?

ខ៖ យើងដើរ

ក៖ អូគ្នាប៉ុន្មាននាក់ទៅអ៊ុំ?

ខ៖ ហាសគ្នារាប់រយនាក់ហោស

ក៖ អូដើរទៅទាំងអស់គ្នាប៉ុន្មានថ្ងៃទៅដល់ទៅអ៊ុំ?

ខ៖ អូមិនដឹងប៉ុន្មានថ្ងៃ ប៉ុន្មានខែទេ

ក៖ ប៉ុន្មានខែ?

ខ៖ យើងគ្មានស្គាល់អីទេ

ក៖ ប៉ុន្មានពេលណុងយើងវិចអង្ករ នឹងវិចបាយទៅដែរមែនទេអ៊ុំ?

ខ៖ អត់មានទេ ដូចថាអង្ករគេដាក់ផ្សេងចឹង
ដល់ពេលកន្លែងណាឈប់ទៅនាំគ្នាដាំស៊ីចឹងទៅណា

ក៖ បាទអ៊ុំបាទ អ៊ុំពេលដែរឆ្នាំកៅជាងនឹងអ៊ុំធ្វើអីទៅអ៊ុំ?

ខ៖ អ៊ុំកៅជាងមកភ្នំពេញនឹង

ក៖ អ៊ុំចាប់ផ្តើមមកភ្នំពេញនៅឆ្នាំកៅជាងណាអ៊ុំ?

ខ៖ ចាហោប៉ែតជាងខ្ញុំមក

ក៖ អូអ៊ុំមកប៉ែតជាង ចុះប៉ែតជាងនឹងអ៊ុំមកនៅណាទៅ?

ខ៖ ខ្ញុំមកនៅទួលទំពុងនឹង ខ្ញុំដើរទៅរើសអេតចាយ

ក៖ អូអ៊ុំនៅរើសអេតចាយហោសអ៊ុំ បន្ទាប់ពីបានប៉ុន្មានឆ្នាំទៅបានអ៊ុំមកនៅនឹងវិញទៅអ៊ុំ?

ខ៖ រើសអេតចាយមកចិញ្ចឹមម៉ែឪនឹង

ក៖ ប៉ុន្តែពេលណុងអ៊ុំមានគ្រួសារនៅអ៊ុំ?

ខ៖ ពេលណុងនៅទេ ពេលណុងនៅរើសអេតចាយដើម្បីយកមកដូរអង្ករហាស

ក៖ បាតអ៊ុំកាលពីជំនាន់ណុងគេអត់ទាន់មានចាយលុយណាហីអ៊ុំ?

ខ៖ គេអត់ទាន់បានចាយលុយទេ

ក៖ គេទៅទិញរបស់ទៅដូរអង្ករ

ខ៖
នឹងហើយយើងទៅភ្នំពេញចឹងទៅយកក្បាលម៉ាស៊ីនដេរចឹងទៅយកអាណាស្លាប់ៗអាណារស់ៗចឹងទៅយកទៅបាញ់ចោលហាសកាលពីជំនាន់ណុង
យើងយកម៉ាស៊ីនដេរមួយចឹងទៅ បានអង្ករ10កំប៉ុងហាស

ក៖ អូបាទអ៊ុំ ចុះអ៊ុំឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរអ៊ុំ?

ខ៖ ហេវេទនាមែនទែនទៅណាស់ ក្នុងឆាកជីវិតរបស់ខ្ញុំនឹង

ក៖ ចឹងហោសអ៊ុំ?

ខ៖ ចាដូចថាយើងអត់មាននរណាគេគ្រប់គ្រងហាស

ក៖ បាទអ៊ុំ
ចុះពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់អ៊ុំដែរអ៊ុំ?

ខ៖ អើរខ្ញុំមួយជីវិតនេះអត់សប្បាយទេ ដល់ពេលកូនធំឡើង
យើងខំចិញ្ចឹមវាពេលធំឡើងវាប្រព្រឹត្តអំពើដូចថាវាខុសច្បាប់ហាស
វាប្រើថ្នាំញៀនប្រើអីចឹងវាមិនអោយមានការស្រលាញ់ពីយើងទេ

ក៖ បាទអ៊ុំ ចុះអ៊ុំធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងអ៊ុំចង់ធ្វើអីទេអ៊ុំ?

ខ៖
បើនិយាយអាការស្រម៉ៃខ្ញុំអត់មានបើអាការស្រម៉ៃធំឡើងថាធ្វើអីអត់ពីព្រោះអីយើងទីមួយ

យើងអត់ចេះអក្សរ
ទីពីរដូចថាយើងចិញ្ចឹមជីវិតយើងអោយថ្លៃថ្នូរទៅណាកុំអោយគេមើលងាយ អីចឹងទៅណា

ក៖ ចុះប៉ុន្តែមានធ្លាប់មើលគេធ្វើពេទ្យ
ធ្វើគ្រូអីដែរល្អចឹងថ្ងៃណាមួយពេលដែរធំអ៊ុំចង់ធ្វើដែរអីចឹងអ៊ុំមានដែរធ្លាប់គិតអត់អ៊ុំ?

ខ៖ យើងគ្រាន់តែសោកស្តាយ
យើងសោកស្តាយថាពេលដែរយើងកើតទៅវាប៉ះចំសម័យពលពតចឹងទៅណា
ទី2ដល់ពេលដែរយើងធំដឹងក្តីអត់មានចាំជួបបំរុងអោយយើង
អត់មានអ្នកជួយដោះស្រាយត្រូវដោះស្រាយជីវិតខ្លួនអែងរហូតនឹងចឹងទៅ
ដល់ពេលដែរយើងមានប្តីយើងមិនសប្បាយចិត្តជាមួយគេ យើងត្រូវលែងគ្នា
យើងត្រូវចិញ្ចឹមកូននឹងតស៊ូដើម្បីខ្លួនយើងនេះ ដល់ហើយយើងនៅក្នុងអាភាពនឹង
ខ្ញុំអត់មានគិតអីទៅវែងទេ ខ្ញុំគិតថារកមួយថ្ងៃចាយមួយថ្ងៃ

ក៖ អូបាទអ៊ុំ
ចុះបើចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗតើអ៊ុំចង់ផ្តែផ្តាំអីទៅគាត់ដែរដើម្បីអោយគាត់អាចខំប្រឹងរៀន រឺមួយក៏គាត់អាចមានការងារមួយល្អចឹងហាសអ៊ុំ?

ខ៖ បើនិយាយរួមយើងត្រូវតែប្រាប់កូនចៅដែរថា
ខំរៀនបានយើងទៅមុខទៅយើងចង់ធ្វើការងារអីក៏បានដែរ

ក៖ ដូចលក្ខណះថាធ្វើការងារធំល្អចឹងមែនទេអ៊ុំ?

ខ៖ ចានឹងហើយ

ក៖ តែបើយើងអត់ខំរៀនទេយើងនឹងធ្វើការងារធម្មតានឹង?

ខ៖ យើងអត់រៀនអនាគត់យើងអត់មានស្អីទេ

ក៖
ចុះអ៊ុំចង់ផ្តែផ្តាំអីទៅកូនចៅរបស់អ៊ុំថាអោយគាត់ធ្វើម៉េចអោយល្អនៅក្នុងសង្គមចឹងហាសអ៊ុំកុំអោយគាត់ដូចជាប្រើប្រាស់អីផ្សេងអីទៀតចឹងហាស?

ខ៖ ខ្ញុំគ្រាន់តែនិយាយប្រាប់ចៅថាឪហែងវាហួសពេលហើយ ចៅអែងខំរៀនរៀនអោយចេះ ខ្ញុំមិនដឹងថាស្លាប់ថ្ងៃណាអីថ្ងៃណាទេក្មួយ
ចៅអែងរៀនអោយចេះចឹងទៅសំរាប់ចៅអែងចិញ្ចឹមអនាគត់ចៅអែងទៅមុខ

ក៖ អូបាទអ៊ុំ?

ខ៖
ពីព្រោះអីនៅសព្វថ្ងៃនឹងយាយគ្រប់គ្រងនៅពេលដែរអស់ពីចៅអែងចឹងទៅចៅអែងវេទនាហើយចៅចឹងហាស

ក៖ បាទអ៊ុំចឹងមានអីផ្សេងទៀតអត់អ៊ុំ?

ខ៖ អត់មានទេ

ក៖
បាទចឹងជាចុងក្រោយខ្ញុំអរគុណអ៊ុំដែរបានចំណាយពេលវេលាដែរបានពិភាក្សារដែរទាក់ទងទៅនឹងពីប្រវត្តិរបស់អ៊ុំហាសអ៊ុំ
ហើយអរគុណច្រើនដែរអ៊ុំបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់អ៊ុំមួយនឹងចឹងហាសអ៊ុំបាទចឹងខ្ញុំអរគុណច្រើនអ៊ុំ៕៕៕